**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:១២៧
ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣
**សាលដីកា**
លេខ:២១៤
ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៣

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៣ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ........... ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក .............. ជាចៅក្រម
៣-លោក ............. ជាចៅក្រម
៤-លោក .............. ជាចៅក្រមរបាយការណ៍
៥-លោក .............. ជាចៅក្រម
៦-លោក ............... ជាចៅក្រម
៧-លោក ............... ជាចៅក្រម
៨-លោក .............. ជាចៅក្រម
៩-លោក .............. ជាចៅក្រម

**ក្រឡាបញ្ជី**

-កញ្ញា ................

**តំណាងមហាអយ្យការ**

-លោក ................. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះនលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ៣៣(ឈ)ចុះថ្ងៃទី២៦ ខែកុម្ភៈឆ្នាំ ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ១១ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍រវាង:

ដើមចោទឈ្មោះ សស(ជាចុងបណ្តឹងសាទុក្ខ)អាយុ៤៣ឆ្នាំ ជាតិខ្មែរ ភេទប្រុសរបរកស៊ីធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិប៉ាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ឪពុកឈ្មោះឡុង សន (ស) ម្តាយឈ្មោះង៉ែត គ្រែង (ស) ប្រពន្ធឈ្មោះទៀង ស៊ីន មានកូន០៥នាក់។

ចុងចម្លើយឈ្មោះហត (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុសអាយុ៦៣ឆ្នាំ ជាតិខ្មែរ របរកស៊ីធ្វើស្រែ ទីលំនៅភូមប៉ាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។ឪពុកឈ្មោះហោ ង៉ូវ (ស)ម្តាយឈ្មោះកែង នាង(ស)ប្រពន្ធឈ្មោះឌីម្លិះមានតួន០១នាក់។ផ្ទេរសិទ្ធិឲ្យទៅឈ្មោះទៀវ ស៊ីណា ។

មានមេធាវី លោក **ទលុច** ។

**<u>កម្មវត្ថុបណ្តឹង:</u>** ប្តឹងទាមទារដីទំហំ៣៨ម៉ែត្រ x ១២០ម៉ែត្រ

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ១១៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ របស់លោកខៀវ ស៊ីណា ដែលប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៣៣(ឈ) ចុះថ្ងៃទី២៦ ខែកុម្ភៈឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១២៧ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៩៩ របស់ដើមចោទឈ្មោះសសប្តឹង ទាមទារដីពីឈ្មោះហត ទំហំ១២០ម គុណ១០០ម ដោយអាងហេតុថា ដីនេះខ្លួនបានទិញពី ឈ្មោះ ផន ថា,យឹម អាន និង ភិន ប៉ាច កាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៩៨ ។ លុះមកដល់ថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៨ តុលាការខេត្តបន្ទាយមានជ័យបានចេញដីកាសម្រេចតាមពាក្យស្នើសុំ ដោយសម្រេចប្រគល់ដីដែលមានទំហំដូចខាងលើឱ្យឈ្មោះ ហត គ្រប់គ្រងទៅវិញ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៣៥ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០០ របស់តុលាការ ខេត្តបន្ទាយមានជ័យ បានសម្រេចសេចក្តីដូចតទៅ:

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៩៩ របស់ដើមចោទឈ្មោះសសទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បញ្ឈប់សុពលភាពដីកាសម្រេចតាមពាក្យស្នើសុំលេខ៤១ ៧ ដស ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៩ ចាប់ពីពេលនេះតទៅ ។

៣-ប្រគល់ដីទំនាស់ដែលមាននៅក្នុងគំនូសទីតាំងជាក់ស្តែងរបស់ការិយាល័យរៀបចំ ដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកអូរជ្រៅ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៩ មានបណ្តោយ ស្របផ្លូវអភិវឌ្ឍន៍ឃុំប៉ោយប៉ែត ប្រវែងបណ្តោយ១២០ម៉ែត្រគិតពីព្រំប្រទល់ឈ្មោះថាច់ អែ ទៅជើងទទឹងខាងត្បូង៣៨ម៉ែត្រ ទទឹងខាងជើង៤០ម៉ែត្រ ឲ្យដល់ឈ្មោះ សសជាដើមចោទតាមការទាមទារ ។

៤-ទុកសិទ្ធិឲ្យឈ្មោះហត ទាមទារដីរបស់ខ្លួនដែលបានទិញពីឈ្មោះហាញ់ រី នោះវិញបានជាដំរាប ។

៥-ឲ្យឈ្មោះហត សងប្រាក់ប្រដាប់ក្តី៧.០០០រៀល ដែលដើមចោទបានបង់ទុករួចហើយឲ្យដើមចោទវិញ និងឲ្យបង់ពន្ធសមាមាត្រ១ភាគរយលើតម្លៃដីសំរបសំរួល២.០០០.០០០រៀល អត្រាត្រូវបង់ស្មើ ២០.០០០រៀល តាមបញ្ញាតិច្បាប់ ។

សាលក្រមនេះ ជំនុំជំរះជាសាធារណៈចំពោនមុខគូក្តីទុកសិទ្ធិប្តឹង ឧទ្ធរណ៍ពីរខែគិតពីថ្ងៃប្រកាសសាលក្រម ។

បានឃើញបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០០ របស់ឈ្មោះហាត ប្ដឹងមិនសុខចិត្តនឹងត្រង់ចំណុចសេចក្ដីសម្រេចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៧៥ (ក) ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០០ របស់ឈ្មោះហាត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់តែលើកចោលដោយទាស់ និងគតិច្បាប់ ។

២-តម្កល់សាលក្រមលេខ៣៥ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០០ របស់តុលាការខេត្ត បន្ទាយមានជ័យ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល ដែលដើមបណ្ដឹងឧទ្ធរណ៍បានបង់រួចហើយគឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹងចំនួន២.៥៥០រៀល រង្វាន់ក្រឡាបញ្ជី៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ៥.០០០រៀល អាជ្ញាធរតុលាការ៥.០០០រៀល សរុប១៣.០០០រៀល ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ និងកំបាំងមុខចុងចម្លើយបើកផ្លូវប្ដឹងទាស់ និងប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងទាស់ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០០ របស់ឈ្មោះហាត មិនសុខចិត្ត នឹងសាលដីកាលេខ៧៥(ក) ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសាលដីកាលេខ០៩ (ក) ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍បានសម្រេចដូចតទៅ

១-ទទួលពាក្យបណ្ដឹងទាស់ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០០ របស់ឈ្មោះហាត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយទាស់ខុស និងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ៧៥(ក) ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្ដី បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ៧៦ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០១ របស់លោកខៀវ ស៊ីថា តំណាងឲ្យលោកហាត ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៧៥(ក) ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំនុចនៃសេចក្ដីវិនិច្ឆ័យទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ២៦៦ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០២ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១-ទទួលបណ្តឹងសាទុក្ខលេខ៧៦ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០១ របស់ឈ្មោះ ខៀវស៊ីថា ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ០៩(ក)ចុះថ្ងៃទី១២ខែមីនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១៥៩ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០១ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលលោកខៀវ ស៊ីថា បានបង់ទុកនៅតុលាការកំពូល រួចហើយគឺ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវឲ្យដើមចោទសងប្រាក់១៩.០០រៀល នេះទៅចុងចម្លើយវិញ ។

៥-សាលដីកានេះជំនុំជំរះនាសវនាការជាសាធារណៈនៅថ្ងៃទី១៤ខែវិច្ឆិកា ឆ្នាំ២០០២ និងប្រកាសនាថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៣៣(ឈ) ចុះថ្ងៃទី២៦ ខែកុម្ភៈឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលជំនុំជំរះសំណុំរឿងរដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍លេខ១១ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៣ ដោយសាលដីកាលេខ២៦៦ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០២ របស់តុលាការកំពូល ។

២-ទទួលពាក្យបណ្តឹងចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៩៩ របស់ឈ្មោះសសជាដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៣-ប្រគល់ដីទំនាស់ដែលមានក្នុងតំនួសប្លង់ទីតាំងជាក់ស្តែង របស់ការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលស្រុកអូរជ្រៅ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៩ មានបណ្តោយស្របផ្លូវ អភិវឌ្ឍន៍ឃុំហើយបែតប្រវែងបណ្តោយ១២០ម ទទឹងខាងត្បូង៣៨មទទឹងខាងជើង៤០ម ឱ្យទៅឈ្មោះសសគ្រប់គ្រង និងកាន់កាប់តទៅ ។

៤-កាត់យកប្រាក់ប្រដាប់ក្តីដាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ៥.០០០ និងលើអាជ្ញាធរតុលាការ៥.០០០រៀល សរុប១៣.០០០រៀល ។

បង្គាប់ឱ្យឈ្មោះ ហាត បង់ពន្ធសមាមាត្រ១ភាគរយ លើតម្លៃដីទាស់ ។

៥-សាលដីកនេះ ជំនុំជំរះជាសាធារណៈចំពោះមុខគូក្តី នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ ចំពោះមុខដើមចោទឈ្មោះសសកំបាំង មុខមេធាវី ប៉ាង សុជា ការពារឱ្យភាគីចុងចម្លើយឈ្មោះហាត តែចាត់ទុកជាចំពោះមុខ បើកផ្លូវប្តឹង តវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២ លេខ១១៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ របស់លោក ខៀវ ស៊ីណា ដែលប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៣៣(ឈ) ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៣ របស់លោកហាត (ជាម្ចាស់ បណ្តឹងសាទុក្ខ) ។

បានឃើញសារណាតប ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៣ របស់លោកសស(ជាចុង បណ្តឹងសាទុក្ខ) ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈ សាលដីការដ្ឋប្បវេណីលេខ៣៣(ឈ) ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

អាស្រ័យហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះពិនិត្យ និងសម្រេច ។

បានស្តាប់ចម្លើយរបស់អ្នកនាង ខៀវ លីណា (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះនថាៈ បានជាខ្លួនប្តឹងមិនសុខចិត្ត ព្រោះសាលាឧទ្ធរណ៍បានជំនុំជំរះ ប្រគល់ដីរបស់តាខ្លួនឲ្យទៅភាគីម្ខាង ទៀត ព្រោះដីនេះដីតាខ្លួនជាអ្នកទិញពីឈ្មោះហាញ់។ដោយមានកិច្ចសន្យានិងសាក្សីដឹងឮត្រឹមត្រូវ តាមច្បាប់ ។ កាលពីលោកតាខ្លួនទិញដីនេះ ខ្លួនមានអាយុ១៨ឆ្នាំ ខ្លួនបានដឹងឮ ហើយមុននឹងធ្វើលិខិតទិញលក់ ភាគីបាននាំគ្នាទៅចង្អុលបង្ហាញទីតាំងច្បាស់លាស់ ។ ចំពោះការដែលថា ឈ្មោះហាញ់ រី បានដូរដីឲ្យតាខ្លួននេះ គឺគ្មានការដោះដូរដីនោះទេ។ ដីនេះមុនពេលទំនាស់តាខ្លួនជាអ្នកកាន់កាប់សព្វថ្ងៃនេះគឺនៅទំនេរ ។ ខ្លួនជាអ្នកបន្តសិទ្ធិពីលោកតារបស់ខ្លួន ឈ្មោះហាត សុំឲ្យតុលាការជួយរកយុត្តិធម៌ឲ្យខ្លួនផង ព្រោះដីនេះជារបស់តាខ្លួន ។

បានស្តាប់ចម្លើយរបស់លោកសស(ជាចុងបណ្តឹងសាទុក្ខ)នៅពេលជំនុំជំរះថា ខ្លួនបានទិញដីនេះក្នុងខែធ្នូ ឆ្នាំ១៩៩៨ គឺទិញនៅក្នុងក្រុមរបស់ខ្លួនចំងាយពីផ្ទះប្រហែល៧០០ម៉ែត្រ ទៅដីនោះហើយមុននឹងខ្លួនទិញដីនោះ ខ្លួនឃើញច្បាស់ថា តា ហាញ់ រី បានលក់ដីប្រឡំ ហើយមានការ ដោះដូរដីឲ្យតា ហាត ត្រឹមត្រូវហើយទើបខ្លួនទិញ ហើយក្នុងការទិញនេះខ្លួនបានធ្វើច្បាប់ ត្រឹមត្រូវ និងមានព្រំប្រទល់ច្បាស់លាស់ ។ ដីនេះខ្លួនបានកាន់កាប់តាំងពីពេលដែលខ្លួនបានទិញរហូត មកស្រាប់តែថ្ងៃមួយខ្លួនក៏បាន

ឃើញមានក្រដាស់លិខិតរបស់ខេត្តដាក់លើដីនេះកាន់កាប់បណ្តោះអាសន្ន ខ្លួនក៏បានដាក់ពាក្យបញ្តឹងទៅតុលាការនេះផង ។ដីនេះខ្លួនបានទិញពីឈ្មោះ យឹម មាន ឈ្មោះផន ថា និងឈ្មោះភិន ប៉ាច ។ ប៉ុន្តែឈ្មោះភិន ប៉ាច មិនបានផ្តិតមេដៃនេះ គាត់បាន ប្រគល់សិទ្ធិទៅឲ្យឈ្មោះយឹម អាន ជាតំណាង ។ សំណូមពរសូមកាន់កាប់ដីនេះ ជាកម្មសិទ្ធិ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ទូត លុច ថាមេធាវីការពារចុងចម្លើយ នាពេលសវនាការថាដីទំនាស់នេះជាដីព្រៃស៊ុបទ្រុបហើយលោកហាញ់ រី ជាដីនេះជារបស់ខ្លួន ហើយបានលក់ទៅ ឲ្យលោកហាត ក្រោយពីបានចិញតា ហាត បានកាប់ឆ្ការព្រៃ និងគ្រប់គ្រងដីនេះរហូតមក ។ នៅឆ្នាំ១៩៩៨ ក៏មានទំនាស់ជាមួយលោកសសថាគាត់បានទិញដីនេះពីឈ្មោះ ភិន ប៉ាច ទៅវិញហើយនៅពេលប្តឹងទៅតុលាការ ភិន ប៉ាច បានគេចខ្លួនបាត់ ដូច្នេះគ្មានភស្តុតាង រឺឯកសារ គ្រប់គ្រាន់ដើម្បីបញ្ជាក់ថា លោកសសមានសិទ្ធិកាន់កាប់ដីនេះទេ គឺលោកសន សឿនបាន រំលោភយកដីលោកតា ហាត ខុសច្បាប់ ។ គ្មានភស្តុតាងណាបញ្ជាក់ថា ឈ្មោះសសបានទិញដីពីឈ្មោះ ភិន ប៉ាច ទេ ទាំងសាលដីកាតុលាការកំពូល លើកទីមួយ និងរបាយការណ៍ របស់សាលាឧទ្ធរណ៍មានការយល់ឃើញដូចគ្នា ប៉ុន្តែនៅពេលសម្រេចសេចក្តីសាលាឧទ្ធរណ៍បែរជាកាត់ មានលក្ខណៈពុំត្រឹមត្រូវទៅវិញ ខ្លួនពុំបដិសេធសាលដីកាសាលាឧទ្ធរណ៍ចោលជាអសារបង់ សុំទទួល សិទ្ធិលើដីទំនាស់នេះតាមផ្លូវច្បាប់ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវី ចុងចម្លើយ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលើកទី២លេខ១១៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ឈ្មោះខៀវ លីណា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះដល់អង្គសេចក្តីបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលមានអានុភាពផងដែរ ក្នុងរឿងរដ្ឋប្បវេណី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចប្រគល់ដីទំនាស់ តាមគំនូសប្លង់របស់ការិយាល័យ រៀបចំនគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកអូរជ្រៅចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៩ មានបណ្តោយ១២០ម៉ែត្រ ទទឹងខាងត្បូង៣៨ម៉ែត្រ ទទឹងខាងជើង៤០ម៉ែត្រ ទៅឲ្យឈ្មោះសសកាន់កាប់ និងគ្រប់គ្រងដោយអាងហេតុថា ឈ្មោះហាញ់ រី ដែលជាអ្នកលក់ដីឲ្យចុងចម្លើយ បានអះអាងថា ដីដែលខ្លួនលក់ឲ្យចុងចម្លើយនោះពុំមែនជាដីទំនាស់ទេនោះ នោះគឺជាការភ័ន្តច្រឡំពី ព្រោះថាៈ

-តាមលិខិតផ្ទេរដី ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៩៧ លោកហាញ់ រី បានផ្ទេរដីទំហំ២០០ម៉ែត្រ គុណ១២០ម៉ែត្រ ស្ថិតនៅភូមិបាលីលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ មានព្រំប្រទល់ខាងលិចទល់នឹងដីឈ្មោះសុវណ្ណ ខាងកើតទល់ផ្លូវ ខាងជើងទល់ឈ្មោះវិត ខាងត្បូងទល់នឹងឈ្មោះថាត់ អែ ។

-តាមសាក្សីបំភ្លឺ ឈ្មោះថាច់ អែ ដែលមានព្រំប្រទល់ដីជាប់នឹងដីទំនាស់នេះ ហើយដែលជាសាក្សីក្នុងលិខិតផ្ទេរដី ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៩៧ បានបញ្ជាក់ថា ដីទំនាស់នេះគឺពិតជាដីដែលឈ្មោះហាញ់ រី បានផ្ទេរឱ្យឈ្មោះហត ប្រាកដមែន ។

ដូច្នេះចម្លើយផ្ទាល់មាត់របស់លោកហាញ់ រី មិនអាចនាំឱ្យមោឃភាពលិខិតផ្ទេរដីចុះថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៩៧ បានទេ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍យល់ឃើញតាមចម្លើយរបស់លោកហាញ់ រី ថាលោកហាញ់ រី បានផ្តល់ដីថ្នូរទៅឱ្យលោកហត រួចហើយ គឺជាការភ័ន្តច្រឡំពីព្រោះថាក្នុងរឿងក្តីនេះពុំមានភស្តុតាងស្តីពីផ្តល់ដីថ្នូរនេះទេ ហើយចុងចម្លើយក៏បានប្រកែកថា លោកពុំបានទទួលដីថ្នូរ នេះដែរ ។

-យល់ឃើញថា លោកសសក្តី លោកហត ក្តី លោកហាញ់ រី ក្តីសុទ្ធតែបញ្ជាក់ថាពេលខ្លួនទិញលក់ដីនេះ គឺដីនេះជាដីព្រៃនៅឡើយ ។ ប៉ុន្តែតាមសាក្សីបំភ្លឺបានបង្ហាញឱ្យឃើញថា ក្រោយពេលទិញដីហើយឈ្មោះហត បានជួលមនុស្សឱ្យកាប់ឆ្ការហែករានដីនេះ និងបង្កបង្កើនផល ។ ដូច្នេះតាមមាត្រា៦២ និង៧៤ នៃច្បាប់ភូមិបាលចាស់ លោកហត មានសិទ្ធិលើដីទំនាស់ នេះហើយពីព្រោះភាគីដែលអាចមានសិទ្ធិលើដីភោគៈបាន គឺកើតមកពីកិរិយាកាន់កាប់មិនមែនកើតពីការលក់ទិញដីព្រៃទេ ។

-យល់ឃើញថា ការដែលលោកសសប្តឹងទាមទារដីទំនាស់ពីលោក ហត ដោយអាងហេតុថាលោកបានទិញដីទំនាស់នេះពីឈ្មោះឃឹម អាន ឈ្មោះផន ថា និងឈ្មោះភិន ប៉ាច នោះជាការពុំត្រឹមត្រូវទេពីព្រោះថាៈ

១-ដីទំនាស់នេះស្ថិតនៅលើចំណែកដីដែលលោកអេះអាងថា មិញពីឈ្មោះភិន ប៉ាចប៉ុន្តែពុំមានកិច្ចសន្យាឬចម្លើយរបស់ឈ្មោះភិន ប៉ាច ដែលបញ្ជាក់ថា អ្នកស្រីពិតជាបានលក់ដីឱ្យលោកទេ ។

២-កិច្ចសន្យាផ្ទេរសិទ្ធិដីដែលមានហត្ថលេខា ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ១៩៩៨ របស់លោកមេឃុំឈ្មោះអូ សារឿង ពុំមានស្នាមមេដៃអ្នកស្រីភិន ប៉ាច ទេ ហើយលិខិតនេះក៏ត្រូវបានអភិបាលស្រុកអូរជ្រៅបដិសេធតាមលិខិតលេខ៥៩៥សជណ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៩ហើយដែរ។

៣-អ្នកស្រីភិន ប៉ាច ពុំបានចូលខ្លួនមកជានាឱ្យដើមចោទចំពោះមុខតុលាការតាមមាត្រា៤៣ នៃក្រឹត្យ-ច្បាប់លេខ៣៨ ក្រ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ ទេ ។

៤-កិច្ចសន្យាផ្ទេរសិទ្ធិដីវាង ឈ្មោះយឹម អាន និងសសធ្វើក្រោយការផ្ទេរ សិទ្ធិពីឈ្មោះហាញ់ រី និង ឈ្មោះហ តាម ហើយក្រោយការកាប់ឆ្ការ និងបង្កបង្កើនផលរបស់លោក ហត ។ ដូច្នេះដើមចោទពុំអាច មានសិទ្ធិលើដីទំនាសំបានទេ ។

-យល់ឃើញថាពុំមានភស្តុតាងណាបញ្ជាក់ថាឈ្មោះ ភិន ប៉ាច បានកាន់កាប់ដីទំនាស់ទេ មុន លោក ហាញ់ រី លក់ឲ្យលោកហត និងមុនពេលដែលោក សសទាមទារដីនេះ ។

-យល់ឃើញថាសាលដីការដ្ឋប្បវេណីលេខ៣៣(ឈ) ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេមក្តីចំពោះមុខគូក្តី

១- ទទួលបណ្តឹងសាទុក្ខលើកទី២ លេខ១១៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ឈ្មោះខៀវ លីណា ទុកជាត្រឹមត្រូវតាមទម្រង់នឹងគតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៣៣(ឈ) ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ សាលាឧទ្ធរណ៍ទាំងមូល ។

៣-ប្រគល់ដីទំនាស់(គំនូសក្រហម)ដែលមាននៅក្នុងគំនូសប្លង់ទីតាំងជាក់ស្តែងរបស់ ការិយាល័យរៀបចំនគរូបនីយកម្មសំណង់ និងភូមិបាលស្រុកអូរជ្រៅ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៩ មានបណ្តោយ ស្របផ្លូវអភិវឌ្ឍន៍ ប្រវែងបណ្តោយ១២០ម៉ែត្រ ទទឹងខាងត្បូង៣៨ម៉ែត្រ ទទឹងខាងជើង៤០ម៉ែត្រ ឱ្យទៅ លោកហត កាន់កាប់ និងគ្រប់គ្រងតទៅ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលលោកហត បានបង់គឺៈ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវឱ្យ លោកសសសងប្រាក់១៩.០០០រៀលនេះទៅចុងចម្លើយវិញ ។

-បង្គាប់ឲ្យលោកសសបង់ពន្ធសមាមាត្រ១ភាគរយ លើតម្លៃដីទំនាស់ ។

៥- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៣ ។